# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## « តុលាការកំពូលនឹងបើកសវនាការលើបណ្តឹងសារទុក មន្ត្រីជាន់ខ្ពស់សមាគមអាដហុក ៣រូប នៅវេលាម៉ោង៨ព្រឹក ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០២២ »

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ហៅកាត់ថា "**អាដហុក**" មានកិត្តិយសសូមជូនដំណឹងដល់សាធារណៈជន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ ស្ថានទូតអន្តរជាតិ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ជ្រាបថា នៅវេលាម៉ោង ៨:០០ ព្រឹកថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០២២ ខាងមុខនេះ តុលាការកំពូលនឹងបើកសវនាការលើសំណុំរឿងបណ្តឹងសារទុករបស់មន្ត្រីជាន់ខ្ពស់សមាគមអាដហុកចំនួន ០៣ (បី) រូប រួមមានលោក **នី សុខា** លោក **យី សុខសាន្ត** និងលោកស្រី **លឹម មុន្នី** និងអតីតមន្ត្រីអាដហុកចំនួន ០២ (ពីរ) រូបទៀតគឺលោក **ណៃ វ៉ង់ដា** និងលោក **នី ចរិយា** ដែលកន្លងមកត្រូវបានសាលាដំបូងដាក់ពន្ធនាគារ ម្នាក់ៗកំណត់០៥ឆ្នាំ ដោយត្រូវអនុវត្តទោសក្នុងពន្ធនាគាររយៈពេល១៤ (ដប់បួន) ខែ និងសល់ប៉ុន្មានឰ្យ ពីបទ "**សូកប៉ាន់សាក្សី**" ត្រូវបានចាប់ខ្លួនដោយអង្គភាពប្រឆាំងអំពើពុករលួយកាលពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៦ តាមមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារនៅថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៧ ហើយត្រូវបានអ្នកទាំង ៥ រូប ប្តឹងទៅសាលាឧទ្ធរណ៍កាលពីចុងឆ្នាំ២០១៨ ដើម្បីរកយុត្តិធម៌ និងផ្តល់នូវកិត្តិយសដល់ពួកគាត់វិញ ។ បន្ទាប់មក នៅរសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ សាលាឧទ្ធរណ៍ភ្នំពេញ ក៏បានបើកសវនាការជំនុំជំរះលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងប្រាំខាងលើ ដោយលោកចៅក្រមប្រឹក្សាសម្រេចប្រកាសសាលដីកានៅវេលាម៉ោង៨ព្រឹកថ្ងៃទី២៣ ខែឧសភា ដោយតម្កល់ទុកជាបានការទាំងស្រុងនៅសាលក្រមសាលាដំបូង ។ បន្ទាប់ពីប្រកាសសាលដីកានេះ មន្ត្រីជាន់ខ្ពស់សមាគមអាដហុក ៣រូប បានប្តឹងសារទុកទៅតុលាការកំពូល ដើម្បីទាមទាររកយុត្តិធម៌ និងភាពត្រឹមត្រូវជូនពួកគាត់វិញ ទើបព្រឹកម៉ោង៨ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ តុលាការនឹងបើកសវនាការតាមការប្តឹងសារទុកលើករណីនេះ ។

ដូច្នេះ យើងខ្ញុំសូមគោរពអញ្ជើញសាធារណៈជន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ តំណាងស្ថានទូត អ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ ចូលរួមតាមដាន និងឃ្លាំមើលកុំបីខាន ៕

សូមអរគុណ!

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

**លោក ស៊ឹង សែនករុណា : ០៨៦ ៣២៤ ៦៦៦**

**លោក ភិន សារ៉េ : ០៦៨ ៨៣១ ៦៦៦**